ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី ០៨
## របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩

រៀបចំដោយ: នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន
នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

ឧបត្ថម្ភដោយៈ ថវិកាជាតិ

## ១. សេចក្តីផ្តើម

នៅព្រឹកថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី០៨ សម្រាប់ឆ្នាំ២០១៩ ក្រោមការដឹកនាំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ

ដើម្បីពិនិត្យមើលរបាយការណ៍វឌ្ឍនភាព និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍បើកកិច្ចប្រជុំដោយ ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-ចំណាប់អារម្មណ៍របស់ ឯកឧត្តម **តែង គន្ធី** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-ការពិនិត្យឡើងវិញអំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយ ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បង្ហាញជូនដោយលោកវេជ្ជ. **ទេព ណារ៉ុធ** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ។ និង

-បញ្ហាផ្សេងៗ

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងជម្រាបជូនដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសស្តីពីការផ្ទេរតំណែងអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ពីឯកឧត្តម **តែង គន្ធី** មក ឯកឧត្តម **ឈឹម ឃិនដារ៉េត** ដោយសារ ឯកឧត្តម **តែង គន្ធី** ត្រូវចូលនិវត្តន៍ និងទទួលតួនាទីថ្មី ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាមួយគ្នានេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណចំពោះការចូលរួមជាលក្ខណៈពហុវិស័យ រួមជាមួយគំនិតច្នៃប្រឌិត របស់ក្រសួង ស្ថាប័ន ក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងពេលកន្លងមក រហូតទទួលបានជោគជ័យ។

ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍គឺជា រចនាសម្ព័ន្ធថ្នាក់បច្ចេកទេស របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានសមាជិកសមាជិកាថ្នាក់បច្ចេកទេសរបស់ខ្លួន ជាតំណាងពីក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធដែលជាសមាជិករបស់ អ.ជ.ប.ជ.អ ។ ក្រុមប្រឹក្សាបច្ចេកទេស មានមុខងារផ្តល់ការចូលរួមកម្រិតបច្ចេកទេស ដើម្បីឆ្លើយតបក្នុងការប្រយុទ្ធនឹងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និងចូលរួមចំណែកលើកកម្ពស់ការផ្តល់សេវាថែទាំព្យាបាល ជូនដល់បងប្អូនប្រជាពលរដ្ឋដែលរងគ្រោះដោយសារមេរោគអេដស៍ ដើម្បីអ្នកជំងឺអាចទទួលការព្យាបាល កាន់តែជាប់លាប់មានប្រសិទ្ធភាព កាត់បន្ថយបរិមាណមេរោគអេដស៍នៅក្នុងឈាម ការពារកុំឱ្យមានភាពស៊ាំទៅនឹងថ្នាំប្រឆាំងមេរោគអេដស៍ ដែលអ្នកជំងឺត្រូវព្យាបាលពេញក្នុងមួយជីវិត។

ក្នុងនាមប្រធានស្ថាប័នជាតិមានតួនាទី ដឹកនាំ និងសម្របសម្រួលពហុវិស័យប្រយុទ្ធនឹងជំងឺអេដស៍ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានថ្លែងការ កោតសរសើរចំពោះសមាជិក សមាជិកានៃក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលបានចូលរួមចំណែក ផ្តល់គំនិតយោបល់ និងអនុវត្តគោលនយោបាយផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនៅក្នុងវិស័យនៃផ្នែករៀងៗខ្លួន ព្រោះថាការប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវការការចូលរួមទទួលខុសត្រូវ របស់សាមីបុគ្គល ក្រុមគ្រួសារ សហគមន៍ស្ថាប័ន និងវិស័យទាំងអស់។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានថ្លែងការកោតសរសើរ ចំពោះ ឯកឧត្តម **តែង គន្ធី** អនុប្រធាន អ.ជ.ប.ជ.អ ដែលលោកបាន ចំណាយពេលវេលា កម្លាំងកាយ កម្លាំងចិត្ត និងប្រាជ្ញា ដឹកនាំសម្របសម្រួលក្រុមប្រឹក្សាបច្ចេកទេសទទួលបានជោគជ័យ អស់រយៈពេលប្រមាណ១៥ឆ្នាំ ក្នុងតំណែងជាអគ្គលេខាធិការ រហូតពេលឯកឧត្តម ត្រូវចូលនិវត្តន៍ និងទទួលបានការលើកទឹកចិត្តពីរាជរដ្ឋាភិបាលឱ្យទទួលភារកិច្ចថ្មី ជាអនុប្រធានអ.ជ.ប.ជ.អ នាពេលនេះ។

ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានលើកទឹកចិត្ត **ឯកឧត្តមអគ្គលេខាធិការ** ដែលទើបទទួលបានការតែងតាំងថ្មី បន្តដឹកនាំសម្របសម្រួលក្រុមប្រឹក្សាបច្ចេកទេសតាមលំអានល្អៗ និងវិធីសាស្ត្រថ្មីៗក្នុងនាមជាសេនាធិការបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាកិច្ចបន្ត ឯកឧត្តម **តែង គន្ធី** ក៏បានថ្លែងអំណរគុណចំពោះសមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសទាំងអស់ ដែលបានខិតខំប្រឹងប្រែងចូលរួមបំពេញការងារប្រយុទ្ធនឹងជំងឺអេដស៍អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ក្រោមការដឹកនាំរបស់ ឯកឧត្តម ស្របតាមអាណត្តិការងារដែលមានចែងក្នុងអនុក្រឹត្យលេខ១០៩ រហូតទទួលបានជោគជ័យជាច្រើនជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានលក្ខណៈជាពហុវិស័យ។ ឯកឧត្តម ក៏បានស្នើសុំសមាជិក សមាជិកានៃក្រុមប្រឹក្សាបច្ចេកទេសទាំងអស់ បន្តចូលរួមការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្រោមកិច្ចដឹកនាំរបស់ ឯកឧត្តមអគ្គលេខាធិការ ដែលទើបទទួលបានការតែងតាំងថ្មី ដើម្បីសម្រេចគោលដៅដែលបានកំណត់។

ជាកិច្ចបន្ត ឯកឧត្តម **ឈឹម មិនដារ៉េត** បានថ្លែងការគោរពដឹងគុណប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់សេចក្តីទុកចិត្តតែងតាំងឯកឧត្តម ឱ្យទទួលភារកិច្ចដ៏សំខាន់នេះ។

ឯកឧត្តម បានថ្លែងនូវអំណរគុណ និងការគោរពដឹងគុណដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើការបណ្តុះបណ្តាល ជុសខាត់ ជំរុញលើកទឹកចិត្ត និងផ្តល់ឱកាសឱ្យបំពេញកិច្ចការជាច្រើនជូនស្ថាប័ន អស់រយៈពេលជាច្រើនឆ្នាំ និងទីបំផុតបានផ្តល់សេចក្តីទុកចិត្តដ៏ធំធេង ស្នើសុំប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដើម្បីតែងតាំងឯកឧត្តម ឱ្យបានទទួលតំណែងដ៏សំខាន់នាពេលនេះ។

ឯកឧត្តមបានថ្លែងអំណរគុណចំពោះ ឯកឧត្តម **តែង គន្ធី** ដែលបានណែនាំ ជំរុញលើកទឹកចិត្តនាពេលកន្លងមកទាំងស្មារតី និងបច្ចេកទេសរហូតមកដល់ពេលនេះ។ ឯកឧត្តម ក៏បានគោរពកោតសរសើរ ឯកឧត្តម **តែង គន្ធី** ចំពោះកិច្ចដឹកនាំក្រុមប្រឹក្សាបច្ចេកទេសអស់រយៈពេល១៥ឆ្នាំ ក្នុងតួនាទីជាអគ្គលេខាធិការកន្លងមក រហូតទទួលបានជោជ័យធំៗជាច្រើនក្នុងការងារប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ ជំងឺអេដស៍នៅកម្ពុជា។ ក្នុងនាម ឯកឧត្តមជាអគ្គលេខាធិការ ដែលទើបទទួលការតែងតាំងថ្មី ព្រមទាំងសមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសទាំងអស់ នឹងបន្តការងារដ៏ប្រពៃនេះ និងរួមគ្នារកវិធីសាស្ត្រថ្មីៗបន្ថែមទៀតស្របតាមបរិការណ៍នៃការវិវឌ្ឍរបស់មេរោគអេដស៍ ជំងឺអេដស៍ និងការប្រែប្រួលហិរញ្ញប្បទានក្នុង និងក្រៅប្រទេស ឈានឆ្ពោះទៅសម្រេចបានជោគជ័យជាបន្ត ដើម្បីបញ្ចប់បញ្ហាអេដស៍នៅកម្ពុជា។

ឯកឧត្តម ក៏បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានជួយជ្រោមជ្រែង ផ្តល់យោបល់ស្ថាបនា និងលើកទឹកចិត្តតាំងពីពេលចាប់ផ្តើមរហូតមកដល់ពេលនេះ។

ជាកិច្ចបន្ត ឯកឧត្តម **ឈឹម ឃិនដារ៉េត** បានធ្វើការណែនាំខ្លួន ពីប្រវត្តិនៃការសិក្សា និងបទពិសោធន៍ការងារជូនដល់សមាជិក សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសទាំងអស់បានជ្រាប ព្រមទាំងបានធ្វើបទបង្ហាញពីការពិនិត្យឡើងវិញអំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ ដែលមានចែងនៅក្នុងមាត្រា១០៩ អនុក្រឹត្យនៃការរៀបចំ និងការប្រព្រឹត្តិទៅរបស់ អ.ជ.ប.ជ.អ។

ក្រុមប្រឹក្សាបច្ចេកទេស គឺជាជំនួយការបច្ចេកទេស ឱ្យ អគ្គលេខាធិការ អ.ជ.ប.ជ.អ ដែលទទួលការចាត់តាំងដោយ ក្រសួង ស្ថាប័ន ពាក់ព័ន្ធដែលជាសមាជិក អ.ជ.ប.ជ.អ ត្រូវប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ ក្រោមអធិបតីភាពអគ្គលេខាធិការ នៃអ.ជ.ប.ជ.អ ដើម្បី៖

- រៀបចំគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជូនអ.ជ.ប.ជ.អ
- រៀបចំយុទ្ធសាស្ត្រសម្រាប់អនុវត្តគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជូន អ.ជ.ប.ជ.អ
- រៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍
- ជួយណែនាំការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងតម្រូវការនៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែល អ.ជ.ប.ជ.អ ប្រគល់ជូន

សម្រាប់ការងារបន្ត៖

- រៀបចំសេចក្តីសម្រេចសមាសភាពក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ។
- រៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២០ របស់ក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ។
- រៀបចំរបៀបរបបធ្វើការរបស់ក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ។
- បន្តផ្សព្វផ្សាយ និងអនុវត្តសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០១៩។

- បន្តផ្សព្វផ្សាយ និងអនុវត្តលិខិតលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- បន្តចូលរួមការរៀបចំផែនការយុទ្ធសាស្ត្រទូលំទូលាយ ពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៩-២០២៣។

➢ **តំណាងអង្គការវ៉ាក់**: សូមឱ្យមានសមាជិកក្រុមប្រឹក្សាបច្ចេកទេសតាមក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលនិមួយៗមានចំនួនពីររូប (សម្រាប់ជំនួសគ្នាពេលជាប់រវល់) មកចូលរួមប្រជុំឱ្យបានទៀងទាត់ដោយមានការចាត់តាំងឱ្យបានត្រឹមត្រូវ នៅពេលបុគ្គលម្នាក់អវត្តមាន មានអ្នកជំនួសដើម្បីក្តាប់របាយការណ៍ពីស្ថាប័នមករាយការណ៍ជូនអង្គប្រជុំ។

➢ **តំណាងអង្គការសុខភាពបុរសនៅកម្ពុជា**: សូមចូលរួមជាគំនិតលើការកែសម្រួលសមាសភាពក្រុមប្រឹក្សាបច្ចេកទេស មានការចូលរួមគ្រប់ស្ថាប័ន ក្រសួង អង្គការ សង្គមស៊ីវិលផ្សេងៗ តើយើងគួរអញ្ជើញវិស័យឯកជន ចូលរួមក្នុងក្រុមប្រឹក្សាបច្ចេកទេសនេះដែរឬទេ?

➢ **តំណាងអង្គការHP+**: ចង់ឱ្យមានការចូលរួមរបស់លេខាធិកាដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តមកចូលរួមប្រជុំយ៉ាងតិច១ដងក្នុង១ខែ តែមានកត្តាប្រឈមខ្លះដូចជា ពេលវេលា ថវិកាក្នុងការធ្វើដំណើរ ដូច្នេះមិនមែនគ្រប់ខេត្តត្រូវតែអញ្ជើញមកនោះទេ អាស្រ័យលើប្រធានបទ ឬការចាត់ចែងពីខេត្តនោះ មានអ្វីចង់បង្ហាញដល់សមាជិកក្រុមប្រឹក្សាបច្ចេកទេស។

➢ **តំណាងក្រសួងបរិស្ថាន**: គួរអញ្ជើញខេត្តណាដែលទាក់ទងនឹងប្រធានបទ មិនចាំបាច់បញ្ចូលលេខាធិកាដ្ឋានអេដស៍ខេត្តទេ ។

➢ **តំណាងអង្គការ FHI360**: អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មាន Telegram លេខាធិការដ្ឋានអេដស៍រាជធានី ខេត្ត គួរធ្វើបច្ចុប្បន្នភាពព័ត៌មានផ្សេងៗ និងលើកទឹកចិត្តគាត់ឱ្យលើកពីបញ្ហាដែលកើតមានឡើង ជូនថ្នាក់ដឹកនាំដោះស្រាយ។

➢ **តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**: ស្នើសុំឱ្យរកមធ្យោបាយធ្វើការផ្សព្វផ្សាយអំពីមេរោគអេដស៍ ជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព ដោយការចំណាយទាបហើយបានលទ្ធផលខ្ពស់ដូចជាតាមប្រព័ន្ធបណ្តាញសង្គមជាដើម។

ឯកឧត្តមប្រធានអង្គប្រជុំ បានឯកភាពចំពោះការលើកឡើងរបស់សមាជិក សមាជិកា និងសុំលើកយកទៅពិនិត្យសិក្សា និងជម្រាបជូននៅកិច្ចប្រជុំពេលក្រោយ។

ក្នុងរបៀបវារៈបន្ត លោកវេជ្ជបណ្ឌិត **ឆេត ណារ៉ាឌុច** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យវាយតម្លៃ និងស្រាវជ្រាវនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានធ្វើបទបង្ហាញពីរបាយការណ៍សកម្មភាព និងលទ្ធផលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំខែសីហា ឆ្នាំ២០១៩ ៖

**ក- សកម្មភាព និងលទ្ធផលសម្រេចបាន៖**

- ✓ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាស្តីពីការធ្វើសមាហរណកម្ម កម្មវិធីអេដស៍ទៅក្នុងផែនការអភិវឌ្ឍ ឃុំ សង្កាត់ និងវឌ្ឍនភាពនៃការជ្រើសរើសគ្រួសារដែលមានសមាជិកផ្ទុកមេរោគអេដស៍ ដើម្បីទទួលបានប័ណ្ណសមធម៌ នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង។ សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីតំណាងក្រសួងផែនការ ប្រធានកម្មវិធីអេដស៍ខេត្ត មេឃុំ ចៅសង្កាត់ មកពី ៩ ខេត្ត ក្រុង ដែលមានសមាជិកសរុបចំនួន ៦០នាក់។
- ✓ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយអង្គការ HP+ បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការសិក្សាអំពីច្បាប់ និងបទប្បញ្ញត្តិនៃការផ្តល់សេវាសុខាភិបាលរបស់វិស័យឯកជនឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងប្រទេសកម្ពុជា។ គោលបំណងនៃអង្គសិក្ខាសាលា គឺពិនិត្យមើលលើរបកគំហើញនៃការសិក្សា និងពិភាក្សាពីឧបសគ្គ និងឱកាសក្នុងការពង្រឹងការចូលរួមពីវិស័យឯកជនក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសក្នុងដំណាក់ឈានទៅបញ្ចប់អេដស៍នៅឆ្នាំ២០២៥។
- ✓ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងអេដស៍ រួមជាមួយលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្តបាត់ដំបង សហការជាមួយនិងអង្គការ FHI 360 / Linkages បានរៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគោលការណ៍ណែនាំសម្រាប់អ្នកផ្តល់សេវា ក្នុងឆ្លើយតបអំពើហឹង្សាទាក់ទងនឹងយេនឌ័រ និងមេរោគអេដស៍ សម្រាប់ប្រជាជនទូទៅនិងក្រុមប្រឈម ក្នុងក្រុងបាត់ដំបង និងស្រុកសង្កែ។
- ✓ ថ្ងៃទី១៧-១៩ ខែកញ្ញា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីបរិយាកាសគាំទ្រច្បាប់ គោលនយោបាយ និងភារកិច្ចក្នុងការគាំទ្រការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ (សម្រាប់ថ្នាក់ឃុំសង្កាត់) នៅខេត្តកំពត (អ្នកចូលរួម១៧នាក់ មកពី PAS. police, HC អ្នកផ្តល់សេវាសុខភាព និងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ)។

✓ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមការងារបច្ចេកទេសស្តីពីការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងមេរោគអេដស៍សម្រាប់ប្រជាជនទូទៅ និងក្រុមប្រឈមក្នុងខេត្តបាត់ដំបង។ កិច្ចប្រជុំនេះមានការចូលរួមពីមន្ត្រីមកពីសាលាខេត្ត ស្នងការដ្ឋាននគរបាលខេត្ត អធិការនគរបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង មន្ទីរនានា និងសង្គមស៊ីវិល។

✓ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបើកសិក្ខាសាលាស្តីពីការផ្តល់សុពលភាពលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ សម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ នៅសណ្ឋាគារឡឺរ៉ូយ៉ាល់។ បានពិភាក្សា និងទទួលបាននូវធាតុចូលបន្ថែម។

**សកម្មភាពដែលបានអនុវត្តដោយក្រសួងនានា៖**

✓ ក្រសួងបរិស្ថាន៖ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអប់រំអំពីជំងឺអេដស៍ និងគ្រឿងញៀនដែលបានប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម៖

១. ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩នៅមន្ទីរបរិស្ថានរាជធានីភ្នំពេញ និងមន្ទីរបរិស្ថានខេត្តកណ្តាល

២. ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៩ នៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ និងមន្ទីរបរិស្ថានខេត្តតាកែវ

✓ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំសិក្ខាសាលាស្តីពីការលុបបំបាត់ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ នាថ្ងៃទី១០-១១ ខែកញ្ញា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមចំនួន ប្រមាណ៦០នាក់។

✓ ក្រសួងមហាផ្ទៃ៖ បានរៀបចំបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងកាមរោគប្រចាំក្រសួង។

✓ ក្រសួងកិច្ចការនារី៖

- នៅថ្ងៃទី១៨-២០ ខែកញ្ញា ឆ្នាំ២០១៩ បានរៀបចំវេទិកាអប់រំស្តីពីអាហារូបត្ថម្ភ មេរោគអេដស៍ និងជំងឺអេដស៍ និងការថែទាំសុខភាព ការទៅទទួលសេវាថ្នាំប្រឆាំងនឹងមេរោគអេដស៍ ដល់ប្រជាជនគោលដៅរស់នៅខេត្តបន្ទាយមានជ័យ ចំនួន ៣ វេទិកា ចំនួន ៣ឃុំ ក្នុងនោះមានឃុំគោកបិន ឃុំភូមិថ្មី ឃុំបន្ទាយឆ្មារ ដោយមានអ្នកចូលរួមចំនួន៤៨១នាក់ ស្ត្រី២៦៤នាក់ បុរសចំនួន២០៧នាក់។

- បានរៀបចំរបាយការណ៍ស្តីពីស្ត្រី ក្មេងស្រី និងមេរោគអេដស៍ និងជំងឺអេដស៍ ផ្ញើទៅអង្គការសហប្រជាជាតិ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំលើកទី៦៤ របស់អង្គការសហប្រជាជាតិស្តីពីស្ត្រី ក្មេងស្រី និងមេរោគអេដស៍ និងជំងឺអេដស៍។

✓ ក្រសួងសាធារណការ និងដឹកជញ្ជូន៖

- ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០១៩ ក្រសួងបានបើកកិច្ចសិក្ខាសាលាដើម្បីបញ្ជ្រាបកម្មវិធីផ្សព្វផ្សាយ អប់រំ ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងផលប៉ះពាល់ នៃការប្រើប្រាស់គ្រឿងញៀន ខុសច្បាប់ ដល់មន្ត្រីរាជការ បុគ្គលិក កម្មករ នៅមន្ទីរសាធារណការ ខេត្តស្វាយរៀង និងខេត្តព្រៃវែង។
- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ បានរៀបចំកិច្ចប្រជុំចែករំលែកនូវព័ត៌មាន ចំណេះដឹង និងជំរុញឱ្យមានការយល់ដឹងជាសាធារណៈ ដល់មន្ត្រីរាជការ បុគ្គលិក កម្មករ និងការីដឹកជញ្ជូនសរុបចំនួន ៧០នាក់ ស្តីពីមូលហេតុ របៀបនៃការចម្លង ផលវិបាក មធ្យោបាយបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន។
- ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ បានបើកវគ្គអប់រំស្តីពីគ្រឿងញៀន និងការបង្ការមេរោគអេដស៍ ជូនកម្មករ កម្មការិនីរោងចក្រ វ៉ីងស្កាស៊ូ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមចំនួន ៥៦៧ នាក់ ស្រី៥១១ នាក់ ហើយបានចែកឯកសារ និងសម្ភារៈសុវត្ថិភាពចរាចរណ៍មួយចំនួន។

✓ ក្រសួងផែនការ៖ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការយល់ដឹងអំពីជំងឺអេដស៍ និងរួមចំណែកទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅភោជនីយដ្ឋានទន្លេបាសាក់២។ ក្នុងគោលបំណង ចែករំលែកនូវព័ត៌មាន ចំណេះដឹង និងជំរុញឱ្យមានការយល់ដឹងជាសាធារណៈ ដល់មន្ត្រីរាជការ និងក្រុមគ្រួសារ សាច់ញាតិ ស្តីពីមូលហេតុ របៀបនៃការចម្លង ផលវិបាក មធ្យោបាយបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា។

✓ ក្រសួងព័ត៌មាន៖ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩ បានរៀបចំកិច្ចប្រជុំពិនិត្យស្ថានភាពការប្រយុទ្ធទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នាទីស្តីការក្រសួង ដោយមានអ្នកចូលរួមទាំងអស់ចំនួន ៤១រូប រួមមានតំណាងមន្ត្រីរាជការ អ្នកសារព័ត៌មានមកពីអគ្គនាយកដ្ឋានចំនួន៥ ចំណុះឱ្យក្រសួងព័ត៌មាន។

ឯកឧត្តមប្រធានអង្គប្រជុំ បានមានប្រសាសន៍៖

- ជំរុញឱ្យក្រុមការងារបច្ចេកទេសក្រសួង ស្ថាប័ន ខិតខំអនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍ តាមអាណត្តិរៀងៗខ្លួន ដើម្បីមានរបាយការណ៍ជូនមក អ.ជ.ប.ជ.អ
- ជំរុញឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន រាជធានី ខេត្ត រួសរាន់ ផ្តល់របាយការណ៍ត្រីមាសតាមលិខិតស្នើសុំរបស់ អ.ជ.ប.ជ.អ ឱ្យបានពុំទាន់ពេលដើម្បី ចងក្រងជារបាយការណ៍ សម្រាប់កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៩ ដែលនឹងប្រព្រឹត្តនាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ខាងមុខ។
- ជំរុញឱ្យមន្ត្រីបច្ចេកទេស ដែលជាសេនាធិការរបស់ប្រធានគណៈកម្មាការប្រយុទ្ធនឹងជំងឺ អេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ជម្រាបជូនថ្នាក់នាំអំពីកិច្ចការទាំងអស់នេះ ព្រោះ របាយការណ៍នៃកិច្ចប្រជុំពេញអង្គ នឹងត្រូវគោរពរាយការណ៍ជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជ្រាបដ៏ខ្ពង់ខ្ពស់។ លើសពីនេះ របាយការណ៍ដែលបញ្ជូនមកនេះ ត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃ ផ្តល់បណ្ណសរសើរក្នុងថ្ងៃធ្វើសន្និបាតប្រចាំឆ្នាំ អ.ជ.ប.ជ.អ នាថ្ងៃទី៦ ខែវិច្ឆិកា បន្ទាប់មកផងដែរ។

**ខ- សកម្មភាពបន្ត៖**

- ✓ បញ្ចប់សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (២០១៩-២០២៣)។
- ✓ បញ្ចប់សេចក្តីព្រាងរបាយការណ៍ស្តីពីការអង្កេតការចំណាយប្រយុទ្ធនឹងជំងឺអេដស៍លើកទី៦ ឆ្នាំ ២០១៦-២០១៧ (NASA VI)។
- ✓ បញ្ចប់របាយការណ៍អំពីការសិក្សាសន្ទស្សន៍នៃការមាក់ងាយ និងរើសអើងលើអ្នកផ្ទុកមេរោគ អេដស៍ ២.០ (Stigma Index 2:0)។
- ✓ ត្រៀមរៀបចំកិច្ចប្រជុំពេញអង្គនៃសមាជិក សមាជិកា របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩។
- ✓ រៀបចំរបាយការណ៍វឌ្ឍនភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់កិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ លើកទី២ ឆ្នាំ២០១៩។
- ✓ ត្រៀមរៀបចំសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នាថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩

លោកវេជ្ជ. **ទេព ណារ៉ៃ** បានសុំក្រសួង ស្ថាប័ន រាជធានី ខេត្តផ្តល់របាយការណ៍មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឱ្យបានទៀងទាត់ តាមរយៈ e-mail: naareport@gmail.com និងជួយផ្តល់របាយការណ៍សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩ មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រឹមថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ ដើម្បីបញ្ចូលក្នុងរបាយការណ៍វឌ្ឍនភាពសម្រាប់បង្ហាញក្នុងកិច្ចប្រជុំពេញអង្គលើកទី២ នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៩។

**មតិបូកសរុបរបស់ប្រធានអង្គប្រជុំ៖**

- ស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ ដើម្បីរៀបចំសេចក្តីសម្រេចសមាសភាពក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ
- រៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២០ របស់ក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ
- រៀបចំរបៀបរបបធ្វើការរបស់ក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ
- បន្តផ្សព្វផ្សាយ និងអនុវត្តសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០១៩
- បន្តផ្សព្វផ្សាយ និងអនុវត្តលិខិតលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីវិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- បន្តចូលរួមការរៀបចំផែនការយុទ្ធសាស្ត្រទូលំទូលាយ ពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៩-២០២៣។
- ជួយផ្តល់របាយការណ៍សកម្មភាពប្រចាំខែរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល ដើម្បីបញ្ចូលជារបាយការណ៍រួមរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ជំរុញផ្តល់របាយការណ៍សកម្មភាពប្រចាំខែរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល សម្រាប់កិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈ E-mail naareport@gmail.com ឬ Telegram ដែលផ្តល់ដោយនាយកដ្ឋាន ផែនការ ស្រាវជ្រាវ និងវាយតម្លៃ។
- យើងនឹងមានកិច្ចប្រជុំ និងរកយន្តការណាមួយ ទាក់ទងនឹងជំរុញការផ្សព្វផ្សាយ ដែលមានប្រសិទ្ធិភាពជូនថ្នាក់ដឹកនាំ

- កំណត់កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៩ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ នៅសាលប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាទីបញ្ចប់ ឯកឧត្តមប្រធាន បានថ្លែងអំណរគុណចំពោះសមាជិក សមាជិកានៃកិច្ចប្រជុំ ដែលបានផ្តល់យោបល់យ៉ាងផុសផុលប្រកបដោយការទទួលខុសត្រូវ។ ជាពិសេស ឯកឧត្តម បានលើកទឹកចិត្តឱ្យក្រុមប្រឹក្សាបច្ចេកទេសបន្តធ្វើកិច្ចការរួមគ្នា តាមពាក្យស្លោក "**រួមគ្នា ដើម្បីកម្ពុជាគ្មានអេដស៍**" ។

កិច្ចប្រជុំត្រូវបានបញ្ចប់នៅវេលាម៉ោង១១ និង៣០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

ថ្ងៃច័ន្ទ ៩កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩

**អ្នកធ្វើរបាយការណ៍**

**វេជ្ជ. ហេង ហៃ**

**បានឃើញ និងឯកភាព**

**អគ្គលេខាធិការ**

**ឈឹម ឃិនដារ៉េត**

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ